ព្រះរាជក្រឹត្យ

នស/រកត/០១០៥/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

បង្កើត **រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ** មានអក្សរកាត់ថា " **រ.ប.វ.ត.** " មានឋានៈស្មើរដ្ឋលេខាធិការដ្ឋាន ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ហើយស្ថិតនៅក្រោមវិសាលភាពនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

មាត្រា ២.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានផ្នែកបច្ចេកទេស ស្ថិតក្រោមអាណាព្យាបាលរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង ផ្នែកហិរញ្ញវត្ថុ ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ២
បេសកកម្ម

មាត្រា ៣.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានបេសកកម្មរៀបចំការប្រឡងប្រជែងជ្រើសរើស និង រៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សចៅក្រម និង សិស្សក្រឡាបញ្ជី ដែលបានជ្រើសរើសថ្មី ព្រមទាំងទទួលបន្ទុកបណ្តុះបណ្តាលបន្ត និងធ្វើវិក្រឹតការ ជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដែលកំពុងបំពេញការិយកម្ម ។

មាត្រា ៤.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវសហការល្អជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រសួងយុត្តិធម៌ សាលាជំរះក្តីនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ស្ថាប័នតុលាការអន្តរជាតិ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា ដើម្បីរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ឱ្យឈានទៅជាបណ្តើរៗ រហូតមានកំរិតស្តង់ដារអន្តរជាតិ ។

3/7

ជំពូកទី ៣
រចនាសម្ព័ន្ធ

មាត្រា ៥.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានរចនាសម្ព័ន្ធដូចខាងក្រោមៈ

- **សាលាភូមិន្ទចៅក្រម**
- **សាលាភូមិន្ទក្រឡាបញ្ជី**
- **អគ្គលេខាធិការដ្ឋាន**

ជំពូកទី ៤
តួនាទីភារកិច្ច

មាត្រា ៦.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានតួនាទីភារកិច្ចដូចខាងក្រោមៈ

- រៀបចំផែនការមេនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងក្រឡាបញ្ជី
- រៀបចំ និងអនុម័តផែនការសកម្មភាពអភិវឌ្ឍន៍នៅក្នុងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- កំណត់បែបបទនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រម និង សិស្សក្រឡាបញ្ជី
- ទំនាក់ទំនងធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងក្រឡាបញ្ជី
- អនុម័តបទបញ្ជាផ្ទៃក្នុង
- អនុម័តគំរោងថវិកាប្រចាំឆ្នាំ
- រាយការណ៍ជូនទីស្តីការគណៈរដ្ឋមន្ត្រី តាមកាលកំណត់។

ជំពូកទី ៥
ការគ្រប់គ្រងរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

មាត្រា ៧.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គ្រប់គ្រងដោយក្រុមប្រឹក្សាភិបាល និង ប្រធាននៃរ.ប.វ.ត.មួយរូប ហើយ មានអគ្គលេខាធិការមួយរូប ទទួលបន្ទុកគ្រប់គ្រងរដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ ព្រមទាំងពិនិត្យ និង សម្របសម្រួល ការងាររវាងសាលាភូមិន្ទចៅក្រម និងសាលាភូមិន្ទក្រឡាបញ្ជី ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរៈជនខ្មែរជាន់ខ្ពស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានសញ្ញាប័ត្រខ្ពស់ផ្នែក នីតិសាស្ត្រ ឬ ផ្នែកគ្រប់គ្រង ។

អគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នាយកសាលាភូមិន្ទចៅក្រម និងនាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៨.-

ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវប្រជុំសាមញ្ញចំនួនបីដងក្នុងមួយឆ្នាំ ។ កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ក្រសួងយុត្តិធម៌ ។

មាត្រា ៩.-

ក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានសមាសភាពដូចតទៅ:

១. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	អនុប្រធាន
៣. ប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ	សមាជិកស្ម័យប្រវត្តិ
៤. តំណាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មួយរូប	សមាជិក
៥. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយរូប	សមាជិក
៦. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប	សមាជិក
៧. តំណាងក្រសួងយុត្តិធម៌ មួយរូប	សមាជិក
៨. សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មួយរូប	សមាជិក
៩. ចៅក្រម តុលាការកំពូល មួយរូប	សមាជិក
១០. ចៅក្រម សាលាឧទ្ធរណ៍ មួយរូប	សមាជិក
១១. តំណាងអគ្គស្នងការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មួយរូប	សមាជិក
១២. នាយកសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ	សមាជិកអញ្ជើញ
១៣. នាយកសាលាភូមិន្ទក្រឡាបញ្ជីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ	សមាជិកអញ្ជើញ

១៤. អគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សមាជិកអញ្ជើញ

សមាជិកអញ្ជើញត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែពុំមានសិទ្ធិធ្វើការបោះឆ្នោតអនុម័តអ្វីឡើយ ។

សមាសភាពក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវតែងតាំងដោយអនុក្រឹត្យ ។

ជំពូកទី ៦

ធនធានហិរញ្ញវត្ថុ

មាត្រា ១០.-

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានថវិកាស្វយ័ត ដែលផ្គត់ផ្គង់ដោយថវិកាជាតិ ។ រ.ប.វ.ត. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពផ្សេងៗ សំរាប់ការចំណាយលើដំណើរការបណ្តុះបណ្តាល សេវារដ្ឋបាល ផ្គត់ផ្គង់សំភារៈបរិក្ខារ និងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ ក្នុងគោលដៅធានាប្រសិទ្ធភាពការងាររបស់ខ្លួន ។

ជំពូកទី ៧

អន្តរប្បញ្ញត្តិ

មាត្រា ១១.-

ក្នុងកាលៈទេសៈចាំបាច់ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អាចទទួលបន្ទុករៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការឯកទេសផ្សេងៗទៀត និងអ្នកជំនួយការតុលាការ ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ១២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៣.-

សម្តេចនាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចតាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។

មាត្រា ១៤.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ល.០៥០១.០២២

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខា ព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា
សុខ អាន

លេខ ១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង ឥវន់

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- លេខាធិការដ្ឋាននៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័នរដ្ឋ
- ឯកសារ- កាលប្បវត្តិ